# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋសភា**

លេខ ...................... .រ.ស.

## សូមក្រាបបង្គំទូលថ្វាយ

**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ** : សំណើសុំដាក់ថ្ងៃទី០៤ ខែមិថុនា ជាទិវាកាន់ទុក្ខ នៃការបាត់បង់ទឹកដីខ្មែរ ។

តបតាមកម្មវត្ថុខាងលើ ទូលព្រះបង្គំយើងខ្ញុំជាអ្នកតំណាងរាស្ត្រ សូមព្រះរាជានុញ្ញាតក្រាបបង្គំទូលថ្វាយព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងទ្រង់ព្រះមេត្តាជ្រាបថា កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩ រដ្ឋាភិបាល និងសភាបារាំងបានកាត់ទឹកដីខ្មែរភាគខាងក្រោម នៃទន្លេមេគង្គដែលយើងធ្លាប់ ហៅថា កម្ពុជាក្រោម ឬកូសាំងស៊ីន មានទំហំ ៦៨៩៦៥ គីឡូម៉ែត្រក្រឡា រួមមាន ២១ខេត្ត ឲ្យទៅវៀតណាមដោយខុសច្បាប់ ។

ចាប់ពីពេលនោះមក រហូតមកដល់សព្វថ្ងៃនេះ ប្រជាពលរដ្ឋខ្មែរត្រូវបានកាត់ផ្តាច់រាល់ការទទួលខុសត្រូវ និងការទំនាក់ទំនងពីការគ្រប់គ្រងរបស់ព្រះរាជាណាចក្រកម្ពុជា ម្ល៉ោះហើយប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមត្រូវបានរស់ក្រោមការគ្រប់គ្រងតាមបែបអនានិគម និងប្រព័ន្ធផ្តាច់ការ ព្រមទាំងមានការគាបសង្កត់គ្រប់បែបសព្វយ៉ាងពីសំណាក់អាជ្ញាធរវៀតណាម ។ រយៈពេល ៦១ឆ្នាំហើយ ដែលប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមរស់នៅវងទុក្ខខ្វោចផ្សារ ឈឺចាប់ឥតមានពេលល្ហែ ដូចកូនកំព្រាម្តាយ ។

ដើម្បីឲ្យកុលបុត្រកុលធីតាខ្មែរជំនាន់ក្រោយចងចាំនូវប្រវត្តិសាស្ត្រដ៏ជូចត់ មិនអាចបំភ្លេចបាន ទូលព្រះបង្គំយើងខ្ញុំស្នើសុំព្រះករុណាព្រះមេត្តាបញ្ចូលថ្ងៃទី០៤ ខែមិថុនា ទៅក្នុងប្រតិទិន្នប្រចាំឆ្នាំ សំរាប់ឲ្យមន្ត្រីរាជការ ក៏ដូចជាប្រជាពលរដ្ឋខ្មែរប្រារព្ធពិធីកាន់ទុក្ខទាំងអស់គ្នា ។

សេចក្តីដូចបានទូលថ្វាយខាងលើ សូមព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងជាទីសក្ការៈ ព្រះមេត្តាពិនិត្យសំណើរបស់ទូលព្រះបង្គំយើងខ្ញុំ ដើម្បីឧត្តមប្រយោជន៍ នៃប្រជាជាតិខ្មែរដោយ ព្រះរាជានុគ្រោះ ។

គួរពុំគួរ សូមព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ទ្រង់ព្រះមេត្តាប្រោស ។

*ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ,ថ្ងៃទី.០៥. ខែមេសា ឆ្នាំ២០១០*

ចម្លងជូន :
- ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា
- ខុទ្ទកាល័យសម្តេចប្រធានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ស្ថានទូតនានាប្រចាំកម្ពុជា
- សារពត៌មានជាតិ-អន្តរជាតិ
- ឯកសារ-កាលប្បវត្តិ

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : ( ៨៥៥-២៣ ) ២១៣ ៥៣៥, ២២០ ៦២៨, ទូរសារ : ( ៨៥៥-២៣ ) ២២០ ៦២៥